មេរៀនទី៩

# អ្នកបំរើព្រះត្រូវតែស្អាតស្អំ

*ហេតុអ្វីយើងត្រូវតែស្អាតស្អំក្នុងគ្រប់ប្រការ? (១)*
*តើស្អាតស្អំខាងវិញ្ញាណមានន័យយ៉ាងណា? (២)*
*ចុះឯស្អាតស្អំខាងសីលធម៌? (៣) ស្អាតស្អំខាងចិត្ត? (៤) ស្អាតស្អំខាងរូបកាយ? (៥)*
*តើពាក្យសំដីអាក្រក់បែបណាខ្លះដែលយើងគួរជៀសវាង? (៦)*



១. ព្រះយេហូវ៉ាទ្រង់គឺស្អាតស្អំហើយបរិសុទ្ធ ។ ទ្រង់តម្រូវឲ្យអ្នកថ្វាយបង្គំទ្រង់រមែងនៅស្អាតស្អំ—ខាងវិញ្ញាណ ខាងសីលធម៌ ខាងចិត្ត និងខាងរូបកាយ ។ (ពេត្រុសទី១ ១:១៦) ការនៅស្អាតស្អំចំពោះព្រះនេត្រព្រះគឺជាការពិបាកក្រៃលែង ។ យើងរស់នៅក្នុងពិភពលោកដ៏មិនស្អាតស្អំ ។ យើងក៏មានការតយុទ្ធនឹងខ្លួនរបស់យើងដែលទោរទន់ទៅរកតែការធ្វើខុស ។ ប៉ុន្តែ យើងមិនត្រូវចុះចាញ់ឡើយ ។

២. *សេចក្ដីស្អាតស្អំខាងវិញ្ញាណ៖* បើយើងចង់បំរើព្រះយេហូវ៉ា នោះយើងមិនអាចកាន់ជាប់នឹងសេចក្ដីបង្រៀន ឬទំនៀមទម្លាប់ណាមួយរបស់សាសនាក្លែងក្លាយតទៅទៀតបានឡើយ ។ យើងត្រូវតែចាកចេញពីសាសនាក្លែងក្លាយ ហើយមិនត្រូវគាំទ្រសាសនានេះក្នុងរបៀបណាឲ្យសោះ ។ (កូរិនថូសទី២ ៦:១៤-១៨; វិវរណៈ ១៨:៤) កាលណាយើងបានរៀនសេចក្ដីពិតអំពីព្រះហើយ យើងត្រូវតែប្រយ័ត្នកុំឲ្យខ្លួនយើងត្រូវវង្វេងដោយមនុស្សដែលបង្រៀនសេចក្ដីមិនពិត ។—យ៉ូហានទី២ ១០, ១១

៣. *សេចក្ដីស្អាតស្អំខាងសីលធម៌៖* ព្រះយេហូវ៉ាទ្រង់ចង់ឲ្យអ្នកថ្វាយបង្គំទ្រង់មានចរិយាមារយាទជាគ្រីស្ទាន

ពិតនៅគ្រប់ពេលវេលា ។ (ពេត្រុសទី១ ២:១២) ទ្រង់ទតឃើញគ្រប់អ្វីៗទាំងអស់ដែលយើងធ្វើ សូម្បីធ្វើដោយសម្ងាត់ក៏ដោយ ។ (ហេព្រើរ ៤:១៣) យើងត្រូវតែជៀសវាងអំពើឥតសីលធម៌ខាងការរួមដំណេក និងការប្រព្រឹត្តដ៏ស្មោកគ្រោកឯទៀតនៃលោកីយ៍នេះ ។ —កូរិនថូសទី១ ៦:៩-១១

៤. *សេចក្ដីស្អាតស្អំខាងចិត្ត៖* បើយើងបញ្ចូលក្នុងចិត្តរបស់យើងនូវគំនិតស្អាតស្អំ បរិសុទ្ធ នោះអាកប្បកិរិយារបស់យើងក៏ជាស្អាតស្អំដែរ ។ (ភីលីព ៤:៨) ប៉ុន្ដែ បើយើងរំពឹងគិតតែរបស់ស្មោកគ្រោក នេះនឹងនាំឲ្យកើតមានអំពើអាក្រក់ហើយ ។ (ម៉ាថាយ ១៥:១៨-២០) យើងគួរតែជៀសវាងការកំសាន្ដបែបយ៉ាងណាដែលអាចនាំឲ្យសេចក្ដីស្មោកគ្រោកបង្ខូចដល់ចិត្តយើង ។ យើងអាចបញ្ចូលទៅក្នុងចិត្តយើងនូវគំនិតស្អាតស្អំ ដោយសិក្សាបន្ទូលរបស់ព្រះ ។

៥. *សេចក្ដីស្អាតស្អំខាងរូបកាយ៖* ពីព្រោះពួកគេជាអ្នកតំណាងព្រះ ពួកគ្រីស្ទានគួរតែរក្សាខ្លួនប្រាណនិងសំលៀកបំពាក់គេឲ្យបានស្អាតបាត ។ យើងគួរតែលាងដៃក្រោយពេលប្រើបង្គន់ ហើយគួរលាងដៃមុនពេលបរិភោគឬកាន់ចំណីអាហារផង ។ បើអ្នកឥតមានបង្គន់ត្រឹមត្រូវទេ នោះលាមកគួរតែយកទៅកប់ចោល ។ (ចោទិយកថា ២៣:១២, ១៣) ការរក្សារូបកាយឲ្យបានស្អាតនឹងជួយឲ្យមានសុខភាពល្អ ។ ផ្ទះសម្បែងរបស់គ្រីស្ទានគួរតែរៀបរយស្អាតបាតទាំងក្នុងទាំងក្រៅ គឺគួរតែលេចធ្លុសឡើងជាឧទាហរណ៍ដ៏ល្អមួយក្នុងសហគមន៍ ។

៦. *ពាក្យសំដីស្អាតស្អំ៖* អ្នកបំរើព្រះត្រូវតែនិយាយសេចក្ដីពិតជានិច្ច ។ មនុស្សភូតភរនឹងមិនចូលទៅក្នុងព្រះរាជាណាចក្រនៃព្រះឡើយ ។ (អេភេសូរ ៤:២៥; វិវរណៈ ២១:៨) ពួកគ្រីស្ទានមិនត្រូវប្រើពាក្យអាក្រក់ទេ ។ ពួកគេមិននិយាយប្រាប់ឬស្ដាប់ដល់រឿងលេងសើចដ៏អាសអាភាសឬរឿងស្មោកគ្រោកឡើយ ។ ពួកគេមានសភាពខុសប្លែកពីអ្នកឯទៀតនៅកន្លែងធ្វើការឬនៅឯសាលារៀន ហើយនិងនៅក្នុងសង្កាត់រស់នៅ ដោយព្រោះពាក្យសំដីស្អាតស្អំរបស់គេ ។—អេភេសូរ ៤:២៩, ៣១; ៥:៣

***អ្នកបំរើព្រះត្រូវតែស្អាតស្អំក្នុងគ្រប់ប្រការ***



